# ព្រះរាជក្រម

នស/រកម/១២១៥/០១៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

រដ្ឋសភា
ចូល លេខ ០៤០
ថ្ងៃទី ១១/០១ ឆ្នាំ២០១៦ ម៉ោង
បញ្ជូនទៅ

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្ដីពី
# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង
# ឆ្នាំ ២០១៦

# ជំពូកទី ១
## ថវិកាថ្នាក់ជាតិ

**មាត្រា ១.-**

ត្រូវបានអនុញ្ញាតសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ឲ្យប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិ នូវពន្ធដារ វិភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឲ្យសម្រេចនូវឧបត្ថម្ភធនវិនិយោគ និងការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង "**ក១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន ១៧ ៦១២ ៤៧៧ លាន រៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលចរន្ត........................................................១៣ ៤០៧ ២៦៣ លាន រៀល
- ចំណូលមូលធន......................................................៤ ២០៥ ២១៤ លាន រៀល
  - \+ ចំណូលមូលធនក្នុងប្រទេស.................................១៣០ ៨៦៤ លាន រៀល
  - \+ ចំណូលមូលធនក្រៅប្រទេស............................៤ ០៧៤ ៣៥០ លាន រៀល
    - \- មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ..........................................................២០៣ ០០០ លាន រៀល
    - \- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស .......................................................៣ ៨៧១ ៣៥០ លាន រៀល ។

**មាត្រា ២.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ត្រូវបានកំណត់ស្មើនឹង ១៧ ៤៦២ ៤៧៧ លាន រៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយចរន្ត......................................................១១ ១៥៦ ៩៨៩ លាន រៀល
- ចំណាយមូលធន....................................................៦ ៣០៥ ៤៨៨ លាន រៀល

ក- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

..............................................................១ ៩២៥ ០០០ លាន រៀល

- ដោយថវិកាថ្នាក់ជាតិ...............................១ ៦៧៥ ០០០ លាន រៀល
  - គម្រោងវិនិយោគផ្ទាល់...............១ ២២៤ ០០០ លាន រៀល
  - បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស ..............................................៤៥១ ០០០ លាន រៀល

- ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ

.................................................................២៥០ ០០០ លាន រៀល

ខ- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

.................................................................៣ ៨៧១ ៣៥០ លាន រៀល

គ- ការទូទាត់ការខ្ចី.................................................... ៥០៩ ១៣៨ លាន រៀល ។

**មាត្រា ៣.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយចរន្តថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ត្រូវបានកំណត់ស្មើនឹង ១១ ១៥៦ ៩៨៩ លាន រៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង "**ខ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៤.-**

ចំនួនទឹកប្រាក់នៃឥណទានចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស សម្រាប់ការគ្រប់គ្រងពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៨ ត្រូវបានកំណត់ស្មើនឹង ១៦ ៨៤២ ១៨២ លាន រៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ តាមគម្រោង និងតាមឆ្នាំ ដូចមានចែងក្នុងតារាង "**គ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៥.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយ មូលធនថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ត្រូវបានកំណត់ដូចខាងក្រោម ៖

- ឥណទានភ្ជាប់សន្យា...............................៦ ៣០៥ ៤៨៨ លាន រៀល
- ឥណទានទូទាត់..................................... ៦ ៣០៥ ៤៨៨ លាន រៀល ។

ឥណទាននេះត្រូវបានបែងចែកដូចតទៅ ៖

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ឥណទានភ្ជាប់សន្យា.............................. ១ ៩២៥ ០០០ លាន រៀល
- ឥណទានទូទាត់..................................... ១ ៩២៥ ០០០ លាន រៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

- ឥណទានភ្ជាប់សន្យា...............................៣ ៨៧១ ៣៥០ លាន រៀល

- ឥណទានទូទាត់....................................៣ ៨៧១ ៣៥០ លាន រៀល

គ. ការទូទាត់ការខ្ចី

- ឥណទានភ្ជាប់សន្យា.................................. ៥០៩ ១៣៨ លាន រៀល
- ឥណទានទូទាត់...................................... ៥០៩ ១៣៨ លាន រៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ ដូចមានចែងក្នុងតារាង "**គ២**" និង "**ឃ**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៦.-**

តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ដែលបានរៀបចំនៅក្នុងតារាង "**ក១**" ស្តីពីចំណូលថវិកាថ្នាក់ជាតិ និងតារាង "**ខ១**" ស្តីពីចំណាយថវិកាថ្នាក់ជាតិ ត្រូវបានបង្ហាញនៅក្នុងតារាងកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិដូចខាងក្រោម ៖

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ | ចំនួនទឹកប្រាក់ | តុល្យភាព/ ហិរញ្ញប្បទាន |
|---|---|---|
| I. ចំណូលក្នុងប្រទេសសរុប | ១៣ ៥៣៨ ១២៧ | |
| ១. ចំណូលចរន្ត | ១៣ ៤០៧ ២៦៣ | |
| ២. ចំណូលមូលធនក្នុងប្រទេស | ១៣០ ៨៦៤ | |
| II. ចំណាយថវិកាសរុប | ១៦ ៩៥៣ ៣៣៩ | |
| ១. ចំណាយចរន្ត | ១១ ១៥៦ ៩៨៩ | |
| ២. ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចី) | ៥ ៧៩៦ ៣៥០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ១ ៩២៥ ០០០ | |
| + ដោយថវិកាថ្នាក់ជាតិ | ១ ៦៧៥ ០០០ | |
| - គម្រោងវិនិយោគផ្ទាល់ | ១ ២២៤ ០០០ | |
| - បដិភាគ | ៤៥១ ០០០ | |
| + ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | ២៥០ ០០០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៣ ៨៧១ ៣៥០ | |
| អតិរេកនៃថវិកាចរន្ត (I.១ -II.១) | | +២ ២៥០ ២៧៤ |
| ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ (I-II) | | -៣ ៤១៥ ២១២ |
| III. ហិរញ្ញប្បទាននៃឱនភាព | | +៣ ៤១៥ ២១២ |
| ១. ហិរញ្ញប្បទានក្រៅប្រទេស | | +៣ ៥៦៥ ២១២ |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | +២០៣ ០០០ |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | +៣ ៨៧១ ៣៥០ |
| • ការទូទាត់ការខ្ចី | | -៥០៩ ១៣៨ |
| ២. ហិរញ្ញប្បទានក្នុងប្រទេស | | -១៥០ ០០០ |
| • បញ្ញើរាជរដ្ឋាភិបាល | | -១៩៧ ០០០ |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | +៤៧ ០០០ |

# ជំពូកទី ២

## ការខ្ចី និងការធានារបស់រដ្ឋ

### មាត្រា ៧.-

សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ អនុម័តយល់ព្រមឲ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេក្នុងកម្រិត ៧០០ ០០០ ០០០ SDR (ប្រាំពីររយលានអេសដេអ៊ែរ) ។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកម្រិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ ។

នៅក្នុងលក្ខខណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់ តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងការចុះហត្ថលេខាលើការខ្ចី ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬលើការធានារបស់រដ្ឋ ហើយត្រូវធ្វើរបាយការណ៍ស្ដីពីការអនុវត្តនៃការខ្ចីនិងការធានានេះ ជូនរដ្ឋសភា និងព្រឹទ្ធសភារៀងរាល់ ៦ ខែម្ដង ។

### មាត្រា ៨.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការឯកភាពពីធនាគារជាតិនៃកម្ពុជា ត្រូវបានទទួលការអនុញ្ញាតឲ្យបោះផ្សាយបណ្ណរតនាគារ ក្នុងកម្រិតទឹកប្រាក់ដែលមានស្តុកចំនួន ១០០ ០០០ ០០០ ០០០ រៀល(មួយរយប៊ីលានរៀល) ដើម្បីដោះស្រាយតម្រូវការជាបន្ទាន់ខាងសាច់ប្រាក់ ។ លក្ខខណ្ឌនៃការលក់បណ្ណរតនាគារនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានស្របច្បាប់ ។

### មាត្រា ៩.-

មិនអនុញ្ញាតឲ្យក្រសួង ឬស្ថាប័នសាធារណៈណាមួយចំណុះរដ្ឋ មានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលបត្ររយៈពេលវែង មធ្យម ខ្លី ឬឥណទានអ្នកផ្គត់ផ្គង់ ឬចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬការធានាកិច្ចសន្យា ដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈ ឬឯកជន ឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ ឬតាមឆ្នាំ ដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុ និងលក្ខខណ្ឌទាំងឡាយដែលច្បាប់នេះបានកំណត់នោះទេ ។

ROYAUME DU CAMBODGE * LE SECRETARIAT DU PALAIS ROYAL

# ជំពូកទី ៣

## បទប្បញ្ញត្តិស្តីពីពន្ធដារ

### មាត្រា ១០.-

មាត្រា ៤ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ត្រូវបានកែប្រែដូចខាងក្រោម ៖

មាត្រា ៤.- ថ្មី

របបកំណត់ពន្ធនៃព្រះរាជាណាចក្រកម្ពុជាជារបបស្វ័យប្រកាស ដែលតម្រូវឲ្យអ្នកជាប់ពន្ធធ្វើការគណនាប្រាក់ពន្ធ និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធដោយខ្លួនឯង ។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបានចែកជាបីប្រភេទគឺ អ្នកជាប់ពន្ធតូច អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ ។

វិធាននិងនីតិវិធី ធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមប្រភេទនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើទ្រង់ទ្រាយអាជីវកម្ម និងកម្រិតផលរបរ ។

### មាត្រា ១១.-

មាត្រា ៦ នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ១៩៩៧ ត្រូវបានកែប្រែដូចខាងក្រោម ៖

មាត្រា ៦.- ថ្មី

វិធានគណនេយ្យត្រូវបានកំណត់ដូចខាងក្រោម ៖

អ្នកជាប់ពន្ធតូច ត្រូវប្រើវិធានគណនេយ្យសាមញ្ញ ដែលនឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ ត្រូវប្រើវិធានគណនេយ្យតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ។ ប្រាក់ចំណូលត្រូវគិតបញ្ចូលនៅក្នុងឆ្នាំដែលចំណូលនោះបានកើតឡើង ទោះបីប្រាក់ចំណូលនោះបានទូទាត់ ឬមិនទាន់ទូទាត់ក្តី ។ ការកាត់កងចំណាយណាមួយអាចធ្វើទៅបាន លុះណាតែហេតុការណ៍បញ្ជាក់នូវបន្ទុករបស់អ្នកជាប់ពន្ធបានកើតឡើង លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទងដល់ខ្ទង់ចំណាយនោះបានកើតឡើង និងចំនួនទឹកប្រាក់ដែលជាបន្ទុករបស់អ្នកជាប់ពន្ធអាចបង្ហាញច្បាស់លាស់ ។

ចំណាយនានាធ្វើឡើងចំពោះបុគ្គលទាក់ទិន ដែលមិនស្ថិតក្រោមរបបស្វ័យប្រកាសមិនអនុញ្ញាតឲ្យកាត់កងមុនការទូទាត់ជាក់ស្តែងឡើយ ។

ធនាគារ ស្ថាប័នសញ្ញ័យធន និងស្ថាប័នឥណទានក្នុងស្រុកត្រូវបានអនុញ្ញាតឲ្យធ្វើសំវិធានធនសម្រាប់ឥណទេយ្យជាប់សង្ស័យដើម្បីកំណត់ប្រាក់ចំណេញជាប់ពន្ធ ។ វិធាន និងនីតិវិធីស្តីពីការកាត់កងនានា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## មាត្រា ១២._

ចំនួនប្រាក់ពន្ធប៉ាតង់ដែលបានចែងក្នុងមាត្រា ៣៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤ ត្រូវបានកែប្រែដូចតទៅ ៖

ប្រាក់ពន្ធប៉ាតង់ត្រូវបានកំណត់ដោយផ្អែកលើប្រភេទអ្នកជាប់ពន្ធដូចខាងក្រោម ៖

ក. អ្នកជាប់ពន្ធតូច ត្រូវបង់ប្រាក់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៤០០ ០០០ រៀល (បួនរយពាន់រៀល)

ខ. អ្នកជាប់ពន្ធមធ្យម ត្រូវបង់ប្រាក់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ១ ២០០ ០០០ រៀល (មួយលានពីររយពាន់រៀល)

គ. អ្នកជាប់ពន្ធធំ ត្រូវបង់ប្រាក់ពន្ធប៉ាតង់ប្រចាំឆ្នាំជាអប្បបរមាចំនួន ៣ ០០០ ០០០ រៀល (បីលានរៀល) និងជាអតិបរមាចំនួន ៥ ០០០ ០០០ រៀល (ប្រាំលានរៀល) ។

ពន្ធប៉ាតង់ត្រូវបានកំណត់លើសកម្មភាពអាជីវកម្មនីមួយៗរបស់អ្នកជាប់ពន្ធ ។ សកម្មភាពជាឧបសម្ព័ន្ធនានានៃសកម្មភាពអាជីវកម្មត្រូវបានចាត់ទុកថាជាសកម្មភាពអាជីវកម្មតែមួយ ។ អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់មុខរបរអាជីវកម្មតែមួយនៅក្នុងរាជធានី ខេត្តតែមួយត្រូវបង់ពន្ធប៉ាតង់តែមួយ ។

វិធាន និងនីតិវិធីអនុវត្តការបង់ពន្ធប៉ាតង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## មាត្រា ១៣._

ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទដែលបានកំណត់ដោយមាត្រា ១៤ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០១៩៨/០០១ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៨ និងមាត្រា ១១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៣/០១៥ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ត្រូវបានកែសម្រួលនិងកំណត់ដូចខាងក្រោមនេះ ៖

ល្អុបរចោលការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទចំពោះ ៖

ក. ទោចក្រយានយន្ត និងត្រីចក្រយានយន្តគ្រប់ប្រភេទ

ខ. ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែល

គ. ជលយានយន្តគ្រប់ប្រភេទ ដែលមានកម្លាំងដល់ ១៥០ សេះ ។

កែសម្រួល និងកំណត់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទចំពោះមធ្យោបាយដឹកជញ្ជូនដូចក្នុងតារាងខាងក្រោម ៖

ឯកតា៖ រៀល

| **ប្រភេទមធ្យោបាយដឹកជញ្ជូន និងយានជំនិះ** | **កម្រិតប្រាក់ពន្ធសម្រាប់ ១ ឆ្នាំ ក្នុងមួយគ្រឿង** |
|---|---|
| រថយន្តដឹកទំនិញមានទម្ងន់សរុប [ទម្ងន់រថយន្ត និងទម្ងន់ផ្ទុក (ទំនិញនិងមនុស្ស)] ៖ | |
| ក- ដល់ ៣តោន | ២០០ ០០០ |
| ខ- លើសពី ៣តោន ដល់ ១០តោន | ៥០០ ០០០ |
| គ- លើសពី ១០តោន ដល់ ២០តោន | ១ ០០០ ០០០ |
| ឃ- លើសពី ២០តោន | ២ ០០០ ០០០ |
| រ៉ឺម៉កសណ្តោងដែលមានទម្ងន់សរុប (ទម្ងន់រ៉ឺម៉ក និងទម្ងន់ផ្ទុក) ៖ | |
| ក- ចាប់ពី ៣តោន ដល់ ១០តោន | ៥០០ ០០០ |
| ខ- លើសពី ១០តោន ដល់ ២០តោន | ១ ០០០ ០០០ |
| គ- លើសពី ២០តោន | ២ ០០០ ០០០ |

ចំពោះប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះដទៃទៀត ត្រូវបានរក្សាទុកដដែល ។

វិធាន និងនីតិវិធីលម្អិតសម្រាប់គ្រប់គ្រងប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL

# ជំពូកទី ៤

# ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

## មាត្រា ១៤.-

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ៨៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ និងបទប្បញ្ញត្តិនៃមាត្រា ៣៥ និងមាត្រា ៥៤ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ចំណូល-ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ សរុបចំនួន ១ ៣៣៤ ៥២៥ លាន រៀល ត្រូវបានកំណត់ដូចខាងក្រោមនេះ ៖

**ក.ថវិការបស់រដ្ឋបាលរាជធានី ខេត្ត**

- ចំណូលថវិកាសរុប....................................៩១៤ ៦៣៥ លាន រៀល
  - +ចំណូលចរន្តសរុប....................................៨០៨ ៨៩៤ លាន រៀល
    - -ចំណូលសារពើពន្ធ.............................៧៧៧ ៥០៤ លាន រៀល
    - -ចំណូលមិនមែនសារពើពន្ធ......................៣១ ៣៩០ លាន រៀល
  - +ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ.................. ១០៥ ៧៤១ លាន រៀល ។
- ចំណាយថវិកាសរុប....................................៩១៤ ៦៣៥ លាន រៀល
  - +ចំណាយចរន្ត..........................................៦៨០ ៧៣០ លាន រៀល
  - +ចំណាយមូលធន.......................................១៥២ ៩០៥ លាន រៀល
  - +អតិរេករាជធានី ខេត្ត....................................៨១ ០០០ លាន រៀល ។

ចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត តាមមាតិកាថវិកា ត្រូវបានកំណត់ដូចមានចែងក្នុងតារាង "**ក២**" និងឥណទានចំណាយបែងចែកទៅតាមរដ្ឋបាលរាជធានី ខេត្តនីមួយៗនិងទៅតាមប្រភេទចំណាយ ត្រូវបានកំណត់ដូចមានចែងក្នុងតារាង "**ខ២**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

## ខ.ថវិការបស់រដ្ឋបាលក្រុង ស្រុក

- ចំណូលថវិកាសរុប....................................១១១ ៤៨០ លាន រៀល

  +ចំណូលចរន្តសរុប.................................... ១២ ៣៤៨ លាន រៀល

  -ចំណូលមិនមែនសារពើពន្ធ...................... ១២ ៣៤៨ លាន រៀល

  +ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ..................... ៩៩ ១៣២ លាន រៀល ។

- ចំណាយថវិកាសរុប.................................... ១១១ ៤៨០ លាន រៀល

  +ចំណាយចរន្ត............................................ ១១១ ៤៨០ លាន រៀល ។

## គ.ថវិការបស់រដ្ឋបាលឃុំ សង្កាត់

- ចំណូលថវិកាសរុប.................................... ៣០៨ ៤១០ លាន រៀល

  +ចំណូលឧបត្ថម្ភពីថវិកាជាតិសរុប......................៣០៨ ៤១០ លាន រៀល

  -ចំណូលសង្កាត់ចំណុះរាជធានី......................២០ ៦១១,២ លាន រៀល

  -ចំណូលសង្កាត់ចំណុះក្រុង..........................២៤ ៣៧៦,២ លាន រៀល

  -ចំណូលឃុំ.................................................២៦៣ ៤២២,៦ លាន រៀល ។

- ចំណាយថវិកាសរុប....................................៣០៨ ៤១០ លាន រៀល

  +ចំណាយសរុប............................................៣០៨ ៤១០ លាន រៀល

  -ចំណាយសង្កាត់ចំណុះរាជធានី.................២០ ៦១១,២ លាន រៀល

  -ចំណាយសង្កាត់ចំណុះក្រុង......................២៤ ៣៧៦,២ លាន រៀល

  -ចំណាយឃុំ...................................២៦៣ ៤២២,៦ លាន រៀល ។

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់នីមួយៗក៏ដូចជាការបែងចែកឥណទាននៅផ្ទៃក្នុងថវិកាជាជំពូក គណនី និងអនុគណនី ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។






Deli

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៦.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០១៥

ចារស.១៥៦២.១១៤៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា**
**អូន ព័ន្ធមុនីរ័ត្ន**

លេខៈ ១១៤៤ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ការគ្រប់គ្រងឆ្នាំ២០១៦

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ទឹកប្រាក់ | ភាគរយ |
| សរុបរួមចំណូលថវិកាថ្នាក់ជាតិ (I+II) | | | | 15.135.230,0 | 17.612.477,0 | 2.477.247,0 | 16,4% |
| I. សរុបចំណូលឆ្លងកាត់តេនាគារជាតិ (ក+ខ) | | | | 11.448.230,0 | 13.741.127,0 | 2.292.897,0 | 20,0% |
| ក្នុងនោះចំណូលក្នុងប្រទេស | | | | 11.148.230,0 | 13.538.127,0 | 2.389.897,0 | 21,4% |
| ក. សរុបចំណូលចរន្ត (ក្រ១+ក្រ២) | | | | 11.014.644,0 | 13.407.263,0 | 2.392.619,0 | 21,7% |
| ក្រុមទី១. ចំណូលពិត (ប្រភេទទី១+ប្រភេទទី២) | | | | 11.014.644,0 | 13.407.263,0 | 2.392.619,0 | 21,7% |
| ប្រភេទទី១. ចំណូលសារពើពន្ធ | | | | 9.548.391,1 | 11.555.055,0 | 2.006.663,9 | 21,0% |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 7.587.691,1 | 9.409.455,0 | 1.821.763,9 | 24,0% |
| | 7001 | | ពន្ធផ្ទាល់ (ពន្ធលើផលទុន ប្រាក់ចំណេញ) | 2.069.000,0 | 2.647.310,0 | 578.310,0 | 28,0% |
| | | 70011 | ពន្ធលើប្រាក់ចំណេញ (រូបវន្តបុគ្គល) | | 96.800,0 | 96.800,0 | |
| | | 70012 | ពន្ធលើប្រាក់ចំណេញ (នីតិបុគ្គល) | 1.565.000,0 | 1.881.110,0 | 316.110,0 | 20,2% |
| | | 70013 | ពន្ធលើប្រាក់បៀវត្ស | 385.000,0 | 502.500,0 | 117.500,0 | 30,5% |
| | | 70014 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (រូបវន្តបុគ្គល) | 96.000,0 | 124.100,0 | 28.100,0 | 29,3% |
| | | 70015 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (នីតិបុគ្គល) | 23.000,0 | 42.800,0 | 19.800,0 | 86,1% |
| | 7002 | | ពន្ធប្រយោល | 3.420.000,0 | 4.121.050,0 | 701.050,0 | 20,5% |
| | | 70021 | អាករលើផលរបរ | 33.000,0 | 33.050,0 | 50,0 | 0,2% |
| | | 70022 | អាករលើតម្លៃបន្ថែម | 1.310.000,0 | 1.488.000,0 | 178.000,0 | 13,6% |
| | | 70025 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 550.000,0 | 685.000,0 | 135.000,0 | 24,5% |
| | | 70026 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 1.340.000,0 | 1.669.000,0 | 329.000,0 | 24,6% |
| | | 70027 | អាករលើតម្លៃបន្ថែម របបនាំចូល ទំនិញជាសម្ភារៈកសិកម្ម (ជាបន្ទុករបស់រដ្ឋ) | 187.000,0 | 246.000,0 | 59.000,0 | 31,6% |
| | 7003 | | អាករពិសេស | 1.953.400,0 | 2.594.600,0 | 641.200,0 | 32,8% |
| | | 70031 | អាករពិសេសលើទំនិញមួយចំនួន | 517.000,0 | 619.500,0 | 102.500,0 | 19,8% |
| | | 70032 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 288.200,0 | 339.000,0 | 50.800,0 | 17,6% |
| | | 70033 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 1.075.200,0 | 1.563.400,0 | 488.200,0 | 45,4% |
| | | 70034 | អាករពិសេសលើសេវាមួយចំនួន | 73.000,0 | 72.700,0 | -300,0 | -0,4% |
| | 7004 | | អាករលើសេវាដែលបានកំណត់ | 95.314,0 | | -95.314,0 | -100,0% |
| | | 70041 | អាករលើកាស៊ីណូ | 94.114,0 | | -94.114,0 | -100,0% |
| | | 70042 | អាករលើឆ្នោត | 1.200,0 | | -1.200,0 | -100,0% |
| | 7005 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិឬការអនុវត្តន៍សកម្មភាព | 26.377,1 | | -26.377,1 | -100,0% |
| | | 70052 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | 26.377,1 | | -26.377,1 | -100,0% |
| | 7008 | | ចំណូលសារពើពន្ធផ្សេងៗទៀត | 23.600,0 | 46.495,0 | 22.895,0 | 97,0% |
| | | 70081 | ពន្ធតែមប្រ៍ | 6.100,0 | 7.975,0 | 1.875,0 | 30,7% |
| | | 70082 | ការផាកពិន័យ និងទោសបញ្ញត្តិសារពើពន្ធ | 17.500,0 | 38.520,0 | 21.020,0 | 120,1% |
| 71 | | | ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1.960.700,0 | 2.145.600,0 | 184.900,0 | 9,4% |
| | 7100 | | ពន្ធនិងអាករលើការនាំចូល | 1.671.400,0 | 2.034.000,0 | 362.600,0 | 21,7% |
| | | 71001 | ពន្ធគយពីការនាំចូល | 1.102.000,0 | 1.350.000,0 | 248.000,0 | 22,5% |
| | | 71002 | កម្រៃពីការងារគយ | 51.000,0 | 66.000,0 | 15.000,0 | 29,4% |
| | | 71003 | ពន្ធគយលើផលិតផលគេលសិលា | 260.000,0 | 305.000,0 | 45.000,0 | 17,3% |
| | | 71004 | អាករបន្ថែមលើផលិតផលគេលសិលាសម្រាប់ថែទាំផ្លូវថ្នល់ | 230.000,0 | 275.000,0 | 45.000,0 | 19,6% |
| | | 71005 | ផលនៃការលក់ផ្លែកគយ | 800,0 | 1.000,0 | 200,0 | 25,0% |
| | | 71006 | ពិន័យផ្សេងៗលើការនាំចូល | 26.000,0 | 35.000,0 | 9.000,0 | 34,6% |
| | | 71007 | ពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ (ជាបន្ទុករបស់រដ្ឋ) | 1.600,0 | 2.000,0 | 400,0 | 25,0% |
| | 7101 | | ពន្ធនិងអាករលើការនាំចេញ | 289.300,0 | 111.600,0 | -177.700,0 | -61,4% |
| | | 71011 | អាករលើការនាំចេញឈើ | 126.000,0 | 75.000,0 | -51.000,0 | -40,5% |
| | | 71012 | អាករលើការនាំចេញកៅស៊ូ | 30.000,0 | 33.000,0 | 3.000,0 | 10,0% |



Betu

# ការគ្រប់គ្រងឆ្នាំ២០១៦

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៥ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៦ | ប្រៀបធៀប ទឹកប្រាក់ | ប្រៀបធៀប ភាគរយ |
|---|---|---|---|---|---|---|---|
| | | 71014 | អាករលើការនាំចេញទំនិញផ្សេងៗ | 2.800,0 | 2.900,0 | 100,0 | 3,6% |
| | | 71015 | កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | 130.000,0 | | -130.000,0 | -100,0% |
| | | 71016 | ពិន័យផ្សេងៗពីការនាំចេញ | 500,0 | 700,0 | 200,0 | 40,0% |
| **ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ** | | | | **1.466.252,9** | **1.852.208,0** | **385.955,1** | **26,3%** |
| 72 | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | **124.344,9** | **103.901,6** | **-20.443,3** | **-16,4%** |
| | 7200 | | ផលនៃសម្បទាន និងការជួលដីធ្លី | 113.614,9 | 88.082,0 | -25.532,9 | -22,5% |
| | | 72001 | សម្បទាននេសាទ | 3.000,0 | 3.055,0 | 55,0 | 1,8% |
| | | 72002 | សម្បទានព្រៃឈើ | 39.545,0 | 20.000,0 | -19.545,0 | -49,4% |
| | | 72003 | សម្បទានពីប្រេងកាត | 3.116,0 | 2.564,2 | -551,8 | -17,7% |
| | | 72004 | សម្បទានរ៉ែ | 43.747,7 | 34.800,7 | -8.947,0 | -20,5% |
| | | 72005 | ការជួលដីទំនេរ (មានតែដី) | 24.206,2 | 27.662,1 | 3.455,9 | 14,3% |
| | 7201 | | ផលទុនពីសហគ្រាសសាធារណៈ | 10.730,0 | 15.819,6 | 5.089,6 | 47,4% |
| | | 72012 | ភាគលាភរបស់សហគ្រាសសាធារណៈ | 10.730,0 | 15.751,0 | 5.021,0 | 46,8% |
| | | 72014 | ប្រាក់ជានាក់ប៉ងសង្គម | | 68,6 | 68,6 | |
| 73 | | | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | **1.255.026,5** | **1.657.096,7** | **402.070,2** | **32,0%** |
| | 7300 | | ផលទុនសហគ្រាសសាធារណៈរដ្ឋបាល សេវាដំណើរការ (រកចំណេញ) | 474.378,9 | 545.483,1 | 71.104,2 | 15,0% |
| | | 73001 | ផលទុនរបស់អាកាសចរណ៍ស៊ីវិល | 92.900,0 | 107.000,0 | 14.100,0 | 15,2% |
| | | 73003 | ផលទុននៃសកម្មភាពទេសចរណ៍ | 256.904,5 | 270.687,9 | 13.783,4 | 5,4% |
| | | 73004 | ផលទុននៃសកម្មភាពវប្បធម៌ | 24.887,9 | 27.044,0 | 2.156,1 | 8,7% |
| | | 73005 | ផលទុនពីប្រៃសណីយ៍ និងទូរគមនាគមន៍ | 93.418,0 | 133.635,0 | 40.217,0 | 43,1% |
| | | 73006 | ផលទុនពីវិទ្យុ និងទូរទស្សន៍ | 1.754,3 | 1.736,1 | -18,2 | -1,0% |
| | | 73007 | ផលទុននៃសេវាផ្គត់ផ្គង់អគ្គិសនី និងទឹក | 30,0 | 30,0 | | |
| | | 73008 | ផលទុនផ្សេងៗទៀត | 4.484,2 | 5.350,1 | 865,9 | 19,3% |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | 32.323,9 | 37.280,6 | 4.956,7 | 15,3% |
| | | 73011 | ការលក់សម្ភារៈបរិក្ខារ សម្ភារៈខូចខាត សម្ភារៈសិក្សា | 128,0 | 122,0 | -6,0 | -4,7% |
| | | 73012 | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | 28.290,6 | 36.968,9 | 8.678,3 | 30,7% |
| | | 73013 | ផលបានពីការលក់ទ្រព្យសម្បត្តិកំទេចកំទី សត្វពាហនៈ | 9,1 | | -9,1 | -100,0% |
| | | 73018 | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ ផ្សេងៗទៀត | 3.896,2 | 189,7 | -3.706,5 | -95,1% |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល | 670.152,9 | 670.770,7 | 617,8 | 0,1% |
| | | 73021 | អាករស្នាក់ទូត (លិខិតឆ្លងដែននិងទិដ្ឋាការ) | 530.347,0 | 506.778,0 | -23.569,0 | -4,4% |
| | | 73023 | ផលពីការបង្កើតសហគ្រាស | 12.339,3 | 17.926,0 | 5.586,7 | 45,3% |
| | | 73024 | ផលពីការបង់សិទ្ធិប្រឡង | 1.046,0 | 6.428,0 | 5.382,0 | 514,5% |
| | | 73025 | ផលពីការលក់ស្លាកលេខ | 25.814,2 | 32.945,0 | 7.130,8 | 27,6% |
| | | 73026 | ចំណូលពីប្រដាប់ក្តី | 3.165,1 | 3.273,5 | 108,4 | 3,4% |
| | | 73027 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាននិងសេវាត្រួតពិនិត្យអនាម័យសត្វ | 95.496,0 | 101.322,9 | 5.826,9 | 6,1% |
| | | 73028 | ចំណូលពីការអនុញ្ញាតិរដ្ឋបាល ទំរង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ | 1.945,3 | 2.097,3 | 152,0 | 7,8% |
| | 7303 | | ការជួលទ្រព្យសម្បត្តិអចល័ត | 16.289,5 | 21.602,3 | 5.312,8 | 32,6% |
| | | 73031 | ការជួលសហគ្រាសសាធារណៈនៅថ្នាក់រដ្ឋបាលកណ្តាល | 5.245,4 | 4.781,4 | -464,0 | -8,8% |
| | | 73032 | ការជួលសហគ្រាសសាធារណៈនៅថ្នាក់ខេត្ត (មន្ទីរជំនាញ) | 9,6 | 9,6 | | |
| | | 73033 | ការជួលសម្ភារៈ និងមធ្យោបាយដឹកជញ្ជូន | 2,9 | 2,9 | | |
| | | 73034 | ការជួលអចលនវត្ថុ (អសង្ហារឹម) | 10.471,6 | 16.808,4 | 6.336,8 | 60,5% |
| | | 73038 | ផលពីការជួលទ្រព្យសម្បត្តិផ្សេងៗ | 560,0 | | -560,0 | -100,0% |
| | 7304 | | ការផ្តល់សេវាកម្ម | 61.881,3 | 96.483,6 | 34.602,3 | 55,9% |
| | | 73042 | កម្រៃនៃការថែទាំ | 29.449,9 | 18.914,0 | -10.535,9 | -35,8% |
| | | 73043 | សេវាសុវិយោដ៏ | 20.000,0 | 25.903,6 | 5.903,6 | 29,5% |

# ការគ្រប់គ្រងឆ្នាំ២០១៦

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៥ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៦ | ប្រៀបធៀប ទឹកប្រាក់ | ប្រៀបធៀប ភាគរយ |
|---|---|---|---|---|---|---|---|
| | | 73044 | សេវាសំណង | 7.233,4 | 6.673,4 | -560,0 | -7,7% |
| | | 73045 | សេវាលិខិតថ្កោលទោស | 1.602,0 | 1.809,0 | 207,0 | 12,9% |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | 3.596,0 | 43.183,6 | 39.587,6 | 1100,9% |
| | 7306 | | កម្រៃប្រតិបត្តិការផ្សេងៗទៀត | | 285.476,4 | 285.476,4 | |
| | | 73061 | ចំណូលកាតព្វកិច្ចពីកាស៊ីណូ | | 133.550,0 | 133.550,0 | |
| | | 73062 | ចំណូលកាតព្វកិច្ចពីឆ្នោត | | 1.300,0 | 1.300,0 | |
| | | 73066 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | | 26.851,4 | 26.851,4 | |
| | | 73067 | កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | | 123.775,0 | 123.775,0 | |
| 74 | | | **ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម** | **8.864,4** | **10.537,2** | **1.672,8** | **18,9%** |
| | 7401 | | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 8.864,4 | 10.537,2 | 1.672,8 | 18,9% |
| 75 | | | **ការឧបត្ថម្ភ អំណោយ** | **671,0** | **1.915,5** | **1.244,5** | **185,5%** |
| | 7506 | | ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ | 671,0 | 693,0 | 22,0 | 3,3% |
| | | 75061 | ពីក្រសួង ស្ថាប័ន | 671,0 | 693,0 | 22,0 | 3,3% |
| | 7508 | | ចំណូលចរន្តពីប្រភពផ្សេងៗ | | 1.222,5 | **1.222,5** | |
| 76 | | | **ផលហិរញ្ញវត្ថុ** | **77.346,1** | **78.757,0** | **1.410,9** | **1,8%** |
| | 7601 | | ការប្រាក់នៃការឲ្យខ្ចី | 77.338,0 | 78.748,0 | 1.410,0 | 1,8% |
| | | 76011 | ការប្រាក់លើកម្ចី | 77.338,0 | 78.748,0 | 1.410,0 | 1,8% |
| | 7698 | | ផលហិរញ្ញវត្ថុផ្សេងទៀត | 8,1 | 9,0 | 0,9 | 11,1% |
| **ខ.សរុបចំណូលមូលធន (ក្រុមទី១ + ក្រុមទី២)** | | | | **433.586,0** | **333.864,0** | **-99.722,0** | **-23,0%** |
| **ក្រុមទី១ : ចំណូលពិត (ប្រភេទទី១ + ប្រភេទទី២)** | | | | **433.586,0** | **333.864,0** | **-99.722,0** | **-23,0%** |
| **ប្រភេទទី១ : ចំណូលពីប្រភពផ្ទាល់** | | | | **133.586,0** | **130.864,0** | **-2.722,0** | **-2,0%** |
| 27 | | | **អចលកម្មហិរញ្ញវត្ថុផ្សេងៗ** | **133.586,0** | **130.864,0** | **-2.722,0** | **-2,0%** |
| | 2701 | | ការអោយខ្ចី (ការសងវិញនូវមូលធន) | 133.586,0 | 130.864,0 | -2.722,0 | -2,0% |
| | | 27011 | ការឲ្យខ្ចី ទៅសហគ្រាសសាធារណៈ | | 130.864,0 | 130.864,0 | |
| | | 27018 | ការឲ្យខ្ចីផ្សេងៗ | 133.586,0 | | -133.586,0 | -100,0% |
| **ប្រភេទទី២ : ចំណូលពីប្រភពខាងក្រៅ** | | | | **300.000,0** | **203.000,0** | **-97.000,0** | **-32,3%** |
| 75 | | | **ការឧបត្ថម្ភអំណោយ** | **90.000,0** | **41.000,0** | **-49.000,0** | **-54,4%** |
| | 7514 | | ឧបត្ថម្ភកធនមូលធនពីក្រៅប្រទេសទ្វេភាគីសម្រាប់ចំណាយវិនិយោគ | 49.500,0 | | -49.500,0 | -100,0% |
| | 7515 | | ឧបត្ថម្ភកធនមូលធនពីក្រៅប្រទេសពហុភាគីសម្រាប់ចំណាយវិនិយោគិន | 40.500,0 | 41.000,0 | 500,0 | 1,2% |
| 50 | | | **ការខ្ចីប្រាក់ និងបំណុលប្រហាក់ប្រហែល** | **210.000,0** | **162.000,0** | **-48.000,0** | **-22,9%** |
| | 5002 | | ការខ្ចីក្រៅប្រទេស-ពហុភាគី | 210.000,0 | 162.000,0 | -48.000,0 | -22,9% |
| **II. សរុបចំណូលអនុវត្តក្រៅគេនាគារជាតិ (ក+ខ)** | | | | **3.687.000,0** | **3.871.350,0** | **184.350,0** | **5,0%** |
| **ប្រភេទទី២ : ចំណូលពីប្រភពខាងក្រៅ** | | | | **3.687.000,0** | **3.871.350,0** | **184.350,0** | **5,0%** |
| 75 | | | **ការឧបត្ថម្ភ អំណោយ** | **537.000,0** | **541.989,0** | **4.989,0** | **0,9%** |
| | 7514 | | ឧបត្ថម្ភកធនមូលធនពីក្រៅប្រទេសទ្វេភាគីសម្រាប់ចំណាយវិនិយោគ | 537.000,0 | 541.989,0 | 4.989,0 | 0,9% |
| 50 | | | **ការខ្ចីប្រាក់ និងបំណុលប្រហាក់ប្រហែល** | **3.150.000,0** | **3.329.361,0** | **179.361,0** | **5,7%** |
| | 5002 | | ការខ្ចីក្រៅប្រទេស-ពហុភាគី | 3.150.000,0 | 3.329.361,0 | 179.361,0 | 5,7% |

# ការគ្រប់គ្រងឆ្នាំ២០១៦

## តារាង "ក២"

## ចំណូលថវិការដ្ឋបាលរាជធានី ខេត្ត

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៥ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៦ | ប្រៀបធៀប ទឹកប្រាក់ | ប្រៀបធៀប ភាគរយ |
|---|---|---|---|---|---|---|---|
| **សរុបរួមចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត (ក+ខ)** | | | | 772.017,5 | 914.635,0 | 142.617,5 | 18,5% |
| **ក-សរុបចំណូលចរន្ត (ក្រុមទី១+ក្រុមទី២)** | | | | 772.017,5 | 914.635,0 | 142.617,5 | 18,5% |
| **ក្រុមទី១: ចំណូលពិត (ប្រភេទទី ១+ប្រភេទទី ២)** | | | | 772.017,5 | 914.635,0 | 142.617,5 | 18,5% |
| **ប្រភេទទី ១: ចំណូលសារពើពន្ធ** | | | | 632.300,0 | 777.504,0 | 145.204,0 | 23,0% |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 632.300,0 | 777.504,0 | 145.204,0 | 23,0% |
| | 7003 | | អាករពិសេស | 111.253,0 | 134.482,0 | 23.229,0 | 20,9% |
| | | 70035 | អាករសម្រាប់បំភ្លឺសាធារណៈ | 111.253,0 | 134.482,0 | 23.229,0 | 20,9% |
| | 7004 | | អាករលើសេវាដែលបានកំណត់ | 15.624,0 | 17.665,0 | 2.041,0 | 13,1% |
| | | 70045 | អាករលើការស្នាក់នៅ | 13.207,0 | 15.158,0 | 1.951,0 | 14,8% |
| | | 70046 | ពន្ធសត្តឃាត | 2.417,0 | 2.507,0 | 90,0 | 3,7% |
| | 7005 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិឬការអនុវត្តន៍សកម្មភាព | 174.207,0 | 180.282,0 | 6.075,0 | 3,5% |
| | | 70053 | ពន្ធប៉ាតង់ | 29.090,0 | 33.123,0 | 4.033,0 | 13,9% |
| | | 70054 | ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ | 145.117,0 | 147.159,0 | 2.042,0 | 1,4% |
| | 7006 | | ពន្ធប្រថាប់ត្រា | 227.567,0 | 338.077,0 | 110.510,0 | 48,6% |
| | | 70061 | ពន្ធប្រថាប់ត្រាលើតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ | 214.614,0 | 323.623,0 | 109.009,0 | 50,8% |
| | | 70062 | ពន្ធប្រថាប់ត្រាលើតម្លៃមធ្យោបាយដឹកជញ្ជូនឬយានយន្តចំពោះការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ | 3.310,0 | 4.302,0 | 992,0 | 30,0% |
| | | 70063 | ពន្ធប្រថាប់ត្រាលើតម្លៃភាគហ៊ុនចំពោះការផ្ទេរ | 2.316,0 | 2.349,0 | 33,0 | 1,4% |
| | | 70064 | ពន្ធប្រថាប់ត្រាលើតម្លៃកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវា | 3.422,0 | 4.115,0 | 693,0 | 20,3% |
| | | 70065 | ពន្ធប្រថាប់ត្រាលើលិខិតមានលក្ខណៈគតិយុត្តិ | 3.905,0 | 3.688,0 | -217,0 | -5,6% |
| | 7007 | | ពន្ធលើអចលនទ្រព្យ | 103.649,0 | 106.998,0 | 3.349,0 | 3,2% |
| | | 70071 | ពន្ធលើអចលនទ្រព្យរូបវន្តបុគ្គល | 92.990,0 | 96.038,0 | 3.048,0 | 3,3% |
| | | 70072 | ពន្ធលើអចលនទ្រព្យនីតិបុគ្គល | 6.618,0 | 6.646,0 | 28,0 | 0,4% |
| | | 70073 | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | 4.041,0 | 4.314,0 | 273,0 | 6,8% |
| **ប្រភេទទី ២: ចំណូលមិនមែនសារពើពន្ធ** | | | | 139.717,5 | 137.131,0 | -2.586,5 | -1,9% |
| 72 | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 3.045,0 | 4.287,4 | 1.242,4 | 40,8% |
| | 7200 | | ផលនៃសម្បទាន និងការជួលដីធ្លី | 3.045,0 | 4.287,4 | 1.242,4 | 40,8% |
| | | 72004 | សម្បទានរ៉ែ | 1.221,0 | 2.208,0 | 987,0 | 80,8% |
| | | 72005 | ការជួលដីទំនេរ (មានតែដី) | 10,0 | 0,0 | -10,0 | -100,0% |
| | | 72006 | ចំណូលពីចំណតរថយន្ត | 1.611,4 | 1.647,1 | 35,7 | 2,2% |
| | | 72007 | ចំណូលពីចំណតជលយាន | 184,1 | 303,4 | 119,3 | 64,8% |
| | | 72008 | ផលនៃការជួលដីធ្លីផ្សេងៗ | 18,5 | 128,9 | 110,4 | 596,8% |
| 73 | | | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 22.946,6 | 23.707,9 | 761,3 | 3,3% |
| | 7300 | | ផលទុនសហគ្រាសសាធារណៈរដ្ឋបាល សេវាដំណើរការ(រកចំណេញ) | 11.012,0 | 11.510,0 | 498,0 | 4,5% |
| | | 73008 | ផលទុនផ្សេងៗទៀត | 11.012,0 | 11.510,0 | 498,0 | 4,5% |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | 2,4 | 0,0 | -2,4 | -100,0% |
| | | 73011 | ការលក់សម្ភារៈបរិក្ខារ សម្ភារៈខូចខាត សម្ភារៈសិក្សា | 2,4 | 0,0 | -2,4 | -100,0% |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល | 2.457,5 | 2.949,4 | 491,9 | 20,0% |
| | | 73027 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាននិងសេវាត្រួតពិនិត្យអនាម័យសត្វ | 1.289,0 | 1.417,0 | 128,0 | 9,9% |
| | | 73028 | ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ | 1.168,5 | 1.532,4 | 363,9 | 31,1% |
| | 7303 | | ការជួលទ្រព្យសម្បត្តិអចល័ត | 57,0 | 57,0 | 0,0 | 0,0% |
| | | 73036 | ការជួលគ្រឹះស្ថានសាធារណៈនៅថ្នាក់ក្រោមជាតិ | 57,0 | 57,0 | 0,0 | 0,0% |
| | 7304 | | ការផ្តល់សេវាកម្ម | 1.787,7 | 1.943,0 | 155,3 | 8,7% |
| | | 73043 | សេវា[illegible]ផ្លោដី | 682,9 | 770,0 | 87,1 | 12,8% |

# ការគ្រប់គ្រងឆ្នាំ២០១៦

## តារាង "ក២"

## ចំណូលថវិការដ្ឋបាលរាជធានី ខេត្ត

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ទឹកប្រាក់ | ភាគរយ |
| | | 73044 | សោភ័ណភាព | 102,8 | 75,0 | -27,8 | -27,0% |
| | | 73048 | ផលពីសោហ៊ុយផ្សេងៗទៀត | 1.002,0 | 1.098,0 | 96,0 | 9,6% |
| | 7305 | | ការជួលទ្រព្យសម្បត្តិអចលនៈផ្សេងទៀត | 7.630,0 | 7.248,5 | -381,5 | -5,0% |
| | | 73051 | ចំណូលពីសត្តឃាតដ្ឋាន | 750,0 | 864,6 | 114,6 | 15,3% |
| | | 73052 | ការជួលកន្លែងលក់ដូរក្នុងទីផ្សារ | 2.063,3 | 1.541,4 | -521,9 | -25,3% |
| | | 73053 | ចំណូលពីកំពង់ចម្លង | 1.124,0 | 1.128,4 | 4,4 | 0,4% |
| | | 73054 | ចំណូលពីយៀវគ្រី និងកន្លែងបែងចែកផលិតផល | 152,1 | 194,6 | 42,5 | 27,9% |
| | | 73055 | ចំណូលពីភាស៊ីផ្សារ | 3.540,6 | 3.519,5 | -21,1 | -0,6% |
| 74 | | | **ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម** | **2.397,4** | **3.394,7** | **997,3** | **41,6%** |
| | 7401 | | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 16,0 | 6,0 | -10,0 | -62,5% |
| | 7402 | | ផលពីការទប់ស្កាត់ និងបង្ក្រាបអំពើគេចពន្ធគយ | 2.381,4 | 3.388,7 | 1.007,3 | 42,3% |
| 75 | | | **ការឧបត្ថម្ភ អំណោយ** | **111.328,5** | **105.741,0** | **-5.587,5** | **-5,0%** |
| | 7501 | | ឧបត្ថម្ភកធនពីថ្នាក់ជាតិ | 111.318,5 | 105.741,0 | -5.577,5 | -5,0% |
| | 7507 | | ចំណូលបដិភាគពីប្រជាពលរដ្ឋ-សប្បុរសជន ក្នុងនិងក្រៅប្រទេស | 10,0 | 0,0 | -10,0 | -100,0% |

# ការគ្រប់គ្រងឆ្នាំ២០១៦

## តារាង "ខ១"

## ចំណាយថវិកាថ្នាក់ជាតិ

ឯកតា: លានរៀល

| ក្រសួង ស្ថាប័ន | សរុបរួម ចំណាយ | ចំណាយចរន្ត: សរុប ចំណាយ ចរន្ត | ចំណាយចរន្ត: ប្រភេទទី១ មធ្យោបាយ និងសេវា | ចំណាយចរន្ត: ប្រភេទទី២ បន្ទុក ហិរញ្ញវត្ថុ | ចំណាយចរន្ត: ប្រភេទទី៣ អន្តរាគមន៍ សាធារណៈ | ចំណាយចរន្ត: ប្រភេទទី៤ ចំណាយ ផ្សេងៗ | ចំណាយចរន្ត: ប្រភេទទី៦ ចំណាយមិន បានគ្រោងទុក | ចំណាយមូលធន: សរុប ចំណាយ មូលធន | ចំណាយមូលធន: ប្រភេទទី១ ការទូទាត់ ប្រាក់កម្ចី | ចំណាយមូលធន: ប្រភេទទី២ អចលកម្ម |
|---|---|---|---|---|---|---|---|---|---|---|
| សរុបរួមចំណាយ | 17.462.477,0 | 11.156.989,0 | 8.383.458,9 | 336.479,0 | 1.773.924,9 | 307.909,2 | 355.217,0 | 6.305.488,0 | 509.138,0 | 5.796.350,0 |
| រដ្ឋបាលកណ្តាល | 10.236.342,7 | 7.802.204,7 | 5.182.080,1 | 336.479,0 | 1.621.722,7 | 306.705,9 | 355.217,0 | 2.434.138,0 | 509.138,0 | 1.925.000,0 |
| -ក្នុងនោះគ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល | 240.754,7 | 240.754,7 | | | 240.754,7 | | | 0 | | 0 |
| មន្ទីរជំនាញរាជធានី ខេត្ត | 3.354.784,3 | 3.354.784,3 | 3.201.378,8 | | 152.202,2 | 1.203,3 | | 0 | | 0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 3.871.350,0 | | | | | | | 3.871.350,0 | | 3.871.350,0 |
| ក. វិស័យរដ្ឋបាលទូទៅ | 1.710.390,6 | 1.597.180,0 | 996.051,6 | | 295.776,3 | 305.352,1 | | 113.210,6 | | 113.210,6 |
| រដ្ឋបាលកណ្តាល | 1.471.372,0 | 1.471.372,0 | 870.318,6 | | 295.776,3 | 305.277,1 | | 0 | | 0 |
| -ក្នុងនោះគ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល | 90.534,5 | 90.534,5 | | | 90.534,5 | | | 0 | | 0 |
| មន្ទីរជំនាញរាជធានី ខេត្ត | 125.808,0 | 125.808,0 | 125.733,0 | | | 75,0 | | 0 | | 0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 113.210,6 | | | | | | | 113.210,6 | | 113.210,6 |
| ០១. ព្រះបរមរាជវាំង | 77.259,0 | 77.259,0 | 57.170,0 | | 19.880,0 | 209,0 | | 0 | | 0 |
| ០២. ព្រឹទ្ធសភា | 140.620,2 | 140.620,2 | 136.603,4 | | 3.901,0 | 115,8 | | 0 | | 0 |
| ០៣. រដ្ឋសភា | 58.941,0 | 58.941,0 | 53.861,0 | | 5.000,0 | 80,0 | | 0 | | 0 |
| ០៤. ក្រុមប្រឹក្សាធម្មនុញ្ញ | 8.137,0 | 8.137,0 | 8.063,4 | | 53,3 | 20,3 | | 0 | | 0 |
| ០៥.១. ទីស្តីការគណៈរដ្ឋមន្ត្រី | 412.317,0 | 304.610,0 | 103.148,0 | | 201.312,0 | 150,0 | | 107.707,0 | | 107.707,0 |
| -ក្នុងនោះគ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល | 88.300,0 | 88.300,0 | | | 88.300,0 | | | 0 | | 0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 107.707,0 | | | | | | | 107.707,0 | | 107.707,0 |
| ០៥.៤. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 14.607,0 | 14.607,0 | 14.587,0 | | | 20,0 | | 0 | | 0 |
| ០៨. ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | 29.646,0 | 29.160,0 | 29.124,0 | | | 36,0 | | 486,0 | | 486,0 |
| ១ រដ្ឋបាលកណ្តាល | 16.640,0 | 16.640,0 | 16.620,0 | | | 20,0 | | 0 | | 0 |
| ៥. មន្ទីរជំនាញរាជធានី ខេត្ត | 12.520,0 | 12.520,0 | 12.504,0 | | | 16,0 | | 0 | | 0 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 486,0 | | | | | | | 486,0 | | 486,0 |
| ០៩. ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | 91.825,0 | 91.825,0 | 88.631,0 | | 2.308,0 | 886,0 | | 0 | | 0 |
| ១០. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | 506.592,6 | 502.174,6 | 172.211,9 | | 26.385,0 | 303.577,7 | | 4.418,0 | | 4.418,0 |
| ១. រដ្ឋបាលកណ្តាល | 480.254,6 | 480.254,6 | 150.328,6 | | 26.385,0 | 303.541,0 | | 0 | | 0 |
